ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤២១ ប្រក.កសក

# ប្រកាស

## ស្តីពី

## ការធ្វើប្រតិភូកម្មមុខងារនៃវិស័យកសិកម្ម ជូនការិយាល័យច្រកចេញចូលតែមួយនៅក្រុង-ស្រុកគោលដៅ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋាន កៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញសេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ
- បានឃើញប្រកាសលេខ ៩២៨ ប្រក ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុក ខណ្ឌគោលដៅ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

## សម្រេច

**ប្រការ១** :ត្រូវបានផ្ទេរប្រតិភូកម្មមុខងារពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនដល់ក្រុង ស្រុកគោលដៅដែលមាន ការិយាល័យច្រកចេញចូលតែមួយដើម្បីចេញលិខិតអនុញ្ញាតដូចខាងក្រោម ៖

១-វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ។

២-លិខិតអនុញ្ញាតធ្វើអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្ម។

**ប្រការ២** :មន្ត្រីទទួលបន្ទុកការងារបច្ចេកទេសកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំទម្រង់បែបបទ និងឯកសារដែលពាក់ព័ន្ធផ្សេងៗសម្រាប់បម្រើដល់ការចេញលិខិតអនុញ្ញាតដូចបានចែងក្នុងប្រការ១ខាងលើ។

**ប្រការ៣** : សាលាក្រុង ស្រុកគោលដៅត្រូវធ្វើលិខិតចម្លងស្តីពីការផ្តល់លិខិតអនុញ្ញាតខាងលើ និងផ្តល់របាយការណ៍ស្ថិតិប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំតាមរយៈប្រធានមន្ទីរកសិកម្មរាជធានី-ខេត្តមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ៤** : អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ប្រធានអង្គភាពក្រោមឱវាទក្រសួង ប្រធានមន្ទីរកសិកម្មរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ សី ៣ ឆ្នាំ២០១១

ច័ន្ទ សារុន

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលាខេត្តពាក់ព័ន្ធ
- សាលាក្រុង ស្រុកពាក់ព័ន្ធ
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៦០៧/៤ ស.ណ.ន កសក

# សេចក្តីណែនាំ

## ស្តីពី

## ការអនុវត្តប្រកាសលេខ...៥២១...កសក.ប្រក ចុះថ្ងៃទី ០៤..ខែ ឧ.ភា.ឆ្នាំ ២០១១ ស្តីពីការធ្វើប្រតិភូកម្មមុខងារនៃវិស័យកសិកម្ម ជូនការិយាល័យច្រកចេញចូលតែមួយនៅក្រុង-ស្រុកគោលដៅ

ដើម្បីលើកកម្ពស់គោលការណ៍អភិបាលកិច្ចល្អ ការកែទម្រង់ប្រព័ន្ធរដ្ឋបាល ដោយពង្រីកវិសាលភាពសេវាកម្ម ដែលផ្តល់ដោយរដ្ឋបាលក្រុង ស្រុក ឱ្យបានទូលំទូលាយតាមរយៈការប្រមូលផ្តុំសេវាកម្មទាំងអស់ក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៅការិយាល័យច្រកចេញ-ចូលតែមួយ ក្នុងគោលបំណងបម្រើប្រជាពលរដ្ឋ អាជីវករ ពាណិជ្ជករ ក្រុមហ៊ុន សហគ្រាស និង អង្គការជាតិ អង្គការអន្តរជាតិ ឱ្យមានប្រសិទ្ធភាពទ្រព្យធនធានដែលមានស្រាប់នៅថ្នាក់ក្រុង ស្រុក ទៅតាមនីតិវិធីរដ្ឋបាល ដែលអាចសម្រេចការងារប្រកបដោយប្រសិទ្ធភាព និងមានរយៈពេលខ្លីជាងមុននោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមណែនាំនីតិវិធីសម្រាប់អនុវត្តទម្រង់ បែបបទ និងឯកសារគំរូសម្រាប់មន្ត្រីដែលបំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយដូចខាងក្រោម :

I. ការចេញវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ (ឧបសម្ព័ន្ធទី ១)

**ក . ទម្រង់បែបបទស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ**

- ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វបិទតែមប្រើប្រាំរយរៀល (មានគំរូ) ចំនួន ២ ច្បាប់
- ប្រវត្តិរូបសង្ខេបមានបិទរូបថត ៤ x ៦ របស់អ្នកស្នើសុំ (មានគំរូ) ចំនួន ២ ច្បាប់
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកស្នើសុំ(ថតចម្លង) ចំនួន ២ ច្បាប់
- កិច្ចសន្យាស្តីពីការស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ (មានគំរូ) ចំនួន ២ ច្បាប់

**ខ .វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ**

វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវចុះហត្ថលេខាប្រធានការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក និងចុះទិដ្ឋាការដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក សាមីដូចមានគំរូជូនភ្ជាប់ជាមួយ ។ ការចេញវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វអនុវត្តបានតែក្នុងដែនសមត្ថកិច្ចក្រុង ស្រុកសាមីតែប៉ុណ្ណោះ មិនអាចប្រើប្រាស់ឆ្លងពីក្រុង ស្រុកមួយ ទៅក្រុង ស្រុកមួយ ឬ ពីក្រុង ស្រុក ទៅ រាជធានី-ខេត្ត បានឡើយ ។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

គ .តារាងផ្ដល់ថ្លៃសេវាសម្រាប់ស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វនៅក្រុង ស្រុក គោលដៅ

តារាងថ្លៃសេវាសម្រាប់អតិថិជនស្នើសុំវិញ្ញាបនបត្រអនាម័យ

| ល.រ | បរិយាយ | សន្លឹក | ថ្លៃឯកតា (រៀល) | សរុប | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | **ក-សំណុំបែបបទ** | | | | |
| ១ | ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ | ០២ | ៥០០ | ១០០០ | |
| | **ខ-តែមប្រើប្រែសណិយ៍** | | | | |
| ២ | តែមប្រើប្រែសណិយ៍លើពាក្យសុំ | | ៥០០ | | |
| | **គ-ការចុះប្រតិបត្តិការ** | | | | |
| ៣ | កន្លែងពិនិត្យចម្ងាយជិត | ១ដង | ៥.០០០,០០ | ៥.០០០,០០ | |
| ៤ | កន្លែងពិនិត្យចម្ងាយមធ្យម | ១ដង | ១០.០០០,០០ | ១០.០០០,០០ | |
| ៥ | កន្លែងពិនិត្យចម្ងាយឆ្ងាយ | ១ដង | ២០.០០០,០០ | ២០.០០០,០០ | |
| | **ឃ-ការចេញវិញ្ញាបនបត្រអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ** | | | | |
| ៦ | ថ្លៃការចេញវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ | | ១០.០០០,០០ | ១០.០០០,០០ | |
| ៧ | បង់សោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ | | តាមប្រកាសរួមលេខ ៤៤៥ប្រក.សហវ/កសក ចុះថ្ងៃទី ២៣ កញ្ញា២០០៨ លេខ ៨៨៤ សហវ.ប្រក ចុះថ្ងៃទី ៩ តុលា ២០០៨ | | |

**II. លិខិតអនុញ្ញាតធ្វើអាជីវកម្មលក់ដុំ លក់រាយសម្ភារកសិកម្ម (ឧបសម្ព័ន្ធទី ២)**

**ក- ទម្រង់បែបបទស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្ម**

១- ពាក្យសុំមានបិទតែមប្រើ ( មានគំរូ ) ចំនួន ២ ច្បាប់

២- ប្រវត្តិរូបសង្ខេបរបស់អាជីវករមានបិទរូបថត ៤ x ៦ មានបញ្ជាក់ពីរដ្ឋបាលឃុំ សង្កាត់ ចំនួន ២ ច្បាប់

៣- អត្តសញ្ញាណប័ណ្ណថតចម្លង ចំនួន ២ ច្បាប់

៤- កិច្ចសន្យានៃការធ្វើអាជីវកម្ម (មានគំរូ ) ចំនួន ២ ច្បាប់

៥- លិខិតអនុញ្ញាតដាក់ទីតាំងស្តុក ចេញដោយមន្ទីរបរិស្ថានរាជធានីខេត្ត (សម្រាប់តែថ្នាំកសិកម្ម ) ចំនួន ២ ច្បាប់

៦- សញ្ញាបត្រជំនាញបសុព្យាបាលដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (សម្រាប់តែអាជីវកម្មបើកគ្រឹះស្ថានលក់បសុឱសថ) ចំនួន ២ ច្បាប់

៧-វិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈសម្រាប់អាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្ម (ចេញដោយមន្ទីរកសិកម្មរាជធានី-ខេត្ត និងនាយកដ្ឋានទីផ្សារកសិកម្ម) ចំនួន ២ ច្បាប់

## ខ- លិខិតអនុញ្ញាតលក់ដុំលក់រាយសម្ភារកសិកម្ម

ត្រូវចុះហត្ថលេខាដោយប្រធានការិយាល័យច្រកចេញចូលតែមួយ ក្រុង ស្រុក និងចុះទិដ្ឋាការដោយអភិបាល នៃគណៈអភិបាលក្រុង ស្រុក សាមី ដូចមានគំរូជូនភ្ជាប់ជាមួយ ។

## គ. តារាងថ្លៃសេវាក្នុងប្រតិបត្តិការចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្ម

| ល.រ | រាយមុខសេវា | ចំនួនជង | ថ្លៃឯកតា(រៀល) | សរុប | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| | **ក-សំណុំបែបបទ** | | | | |
| ១ | ពាក្យសុំលិខិតអនុញ្ញាតឱ្យធ្វើ អាជីវកម្មលក់ដុំ-លក់រាយ សម្ភារកសិកម្ម | ០២ | ៥.០០០រ,០០ | ១០.០០០រ,០០ | តាមកម្រិតអនុវត្ត នៅថ្នាក់កណ្តាល |
| ២ | ប្រវត្តិរូបសង្ខេប | ០២ | មិនបង់ប្រាក់ | | មាននៅក្នុងពាក្យស្នើ |
| ៣ | កិច្ចសន្យានៃការធ្វើអាជីវកម្ម លក់ដុំ-លក់រាយសម្ភារកសិកម្ម | ០២ | មិនបង់ប្រាក់ | | សុំលិខិតអនុញ្ញាត ហើយស្រេច |
| | **ខ-តែមប្រិប្រេសណីយ៍** | | | | |
| ៤ | តែមប្រិប្រេសហើយបិទលើ ពាក្យសុំ | | ៥០០រ,០០ | ៥០០រ,០០ | តាមកម្រិតអនុវត្ត នៅថ្នាក់កណ្តាល |
| | **គ-ការចុះប្រតិបត្តិការ** | | | | |
| ៥ | ទីតាំងអាជីវកម្ម(ចម្ងាយជិត) | ១ | ៥.០០០រ០០ | ៥.០០០រ០០ | |
| ៦ | ទីតាំងអាជីវកម្ម(ចម្ងាយមធ្យម) | ១ | ១០.០០០រ០០ | ១០.០០០រ០០ | |
| ៧ | ទីតាំងអាជីវកម្ម(ចម្ងាយឆ្ងាយ) | ១ | ២០.០០០រ០០ | ២០.០០០រ០០ | |
| | **ឃ-ថ្លៃចេញលិខិតអនុញ្ញាត** | | | | |
| ៨ | លិខិតអនុញ្ញាតអាជីវកម្ម | ០១ | ១០.០០០រ០០ | ១០.០០០រ០០ | សុពលភាពរយៈពេល មួយ ឆ្នាំ |
| ៩ | ថ្លៃបង្កាន់ដៃ | ០១ | | | |

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សង្ឃឹម និងជឿជាក់ថាក្រោយពេលទទួលបានសេចក្តីណែនាំនេះ លោកអភិបាលនៃគណៈអភិបាលក្រុង ស្រុកគោលដៅ មន្ត្រីរាជការទទួលខុសត្រូវគ្រប់លំដាប់ថ្នាក់នៃក្រុង ស្រុកគោលដៅ រួមជាមួយអតិថិជន នឹងអនុវត្តតាមនីតិវិធីខាងលើនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១១

**រដ្ឋមន្ត្រី**

**ជ័ន្ទ. សារុន**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងព័ត៌មាន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាលាក្រុង ស្រុកគោលដៅ
- មន្ទីរកសិកម្មរាជធានី-ខេត្ត
- កាលប្បវត្តិ-ឯកសារ